# SUCCESS STORY

## Promote joint actions amongst Subnational Administration (SNA) through developing Joint List of Recommendations on Civic Engagement DM level at Battambong Province



*FGD with CBOs and Citizens to gather their views and perspectives on the effectiveness of Civic Engagement at DM level, Komreing District, Battambang province*



*Half-day Joint Consultation Meeting between SNA and CSOs to develop joint lists of recommendation on Civic Engagement at DM level, Battambang Province*



*One-day technical partnership meeting between SNA and CSOs to develop joint action plan to implement joint lists of recommendations on Civic Engagement at DM level, Battambang Province*

The Cambodian government's Decentralization and Deconcentration (D&D) reform has the objective of strengthening sub-national democratic development in Cambodia. In this regard, a decisive role is played by the councils and their sub-national administrations in the capital, provinces, municipalities, districts, khans and communes/sangkats in order to make decisions to respond to the needs of the citizens. According to the Law of the Management of Commune/Sangkat, the Law on the Election of Commune/Sangkat, the Law on the Management of Capital, Province, Municipality, District and Khan and the Law on the Election of Capital, Province, Municipality, District and Khan Councils, the council acts as a representative for the benefit of the citizens in their jurisdiction. Both female and male citizens are entitled to participate in decision-making processes in order for their needs to be better met. To date and in broad terms: very limited civic engagement at district and municipality level, due to limited opportunities provided by district and municipality administration and lack of or gaps in implementation of civic engagement mechanisms on the supply-side of district/municipality administration, limited scope of decision-making and budget at district-level which has just started to change, lack of citizens and CBOs awareness and understanding of decision-making processes at DM level and opportunities for engagement, and lack of citizen and Community-based Organizations (CBOs), and Civil Society Organizations (CSOs) capacity to make use of existing engagement opportunities, especially at the district-level.

To address those issues and concerns, theCoalition for Partnership in Democratic Development (CPDD) secretariat compiled 7 case studies of Civic Engagement at DM level at Battambang Province as Battambang krong, Banna, Thma Kuol, Bavel, Moung Russei, Kamrieng and ratanak Mondol district based on our members' experiences of Community training organization for Development (CTOD) and Aphivat Strey (AS). The process of citizens/CBOs/CSOs engagement with district and municipality administrations in existing mechanisms was documented through field interviews with CBOs/CSOs/citizens in order to gather perceptions from them. The process of case study development was carried out in 7 partner target districts of Battambang Province. The full study report and 7 list of the recommendations were finalized based on the factual findings from 7 case studies, consultation meetings (SDG) at DM level and field interview with 367 respondents (209 females). The joint list of recommendations between 7 District Administrations and CSOs were developed and endorsed from 7 District Administrations and joint consultation meetings held between Nov and Dec 2021. The joint lists of recommendations were presented to Provincial and National Level during the partnership technical meeting at Provincial and National Workshop on the joint lists of recommendations to priority recommendations for further actions for both levels. The list of joint recommendations between SNAs and CSOs for further implementation to promote the citizen participation mechanisms in all 7 districts were developed and accepted by SNAs in target DM in Battambang.

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ: giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

Coalition for Partnership in Democratic Development

## *ករណីសិក្សាស្តីពី*

# ការជំរុញការអនុវត្តសកម្មភាពរួមគ្នាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) តាមរយៈការបង្កើតបញ្ជីអនុសាសន៍រួមស្តីពីការចូលរួមរបស់ពលរដ្ឋនៅថ្នាក់ក្រុង-ស្រុក



*កិច្ចពិភាក្សាជាក្រុម ជាមួយ CBOs និង ប្រជាពលរដ្ឋដើម្បីប្រមូលទស្សនៈ និងទស្សនៈរបស់ពួកគេលើប្រសិទ្ធភាពនៃការចូលរួមរបស់ពលរដ្ឋនៅថ្នាក់ ក្រុង-ស្រុក ខេត្តបាត់ដំបង*



*កិច្ចប្រជុំពិគ្រោះយោបល់រួមគ្នារយៈពេលកន្លះថ្ងៃរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើតបញ្ជីរួមនៃអនុសាសន៍ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋនៅថ្នាក់ ក្រុង-ស្រុក*



កិច្ចប្រជុំភាពជាដៃគូកម្រិតបច្ចេកទេសរយៈពេលមួយថ្ងៃរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើតផែនការសកម្មភាពរួមគ្នា ដើម្បីអនុវត្តបញ្ជីអនុសាសន៍រួមស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋ*នៅថ្នាក់ ក្រុង-ស្រុក នៅខេត្តបាត់ដំបង*

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) របស់រដ្ឋាភិបាលកម្ពុជាមានគោលបំណងពង្រឹងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅកម្ពុជា។ ក្នុងន័យនេះ ក្រុមប្រឹក្សា និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវដើរតួនាទីយ៉ាងម៉ឺងម៉ាត់ក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការសម្រេចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ យោងតាមច្បាប់ នៃការគ្រប់គ្រងឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតឃុំសង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតរាជធានី-ខេត្ត។ ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាធ្វើជាតំណាងដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ប្រជាពលរដ្ឋទាំងស្ត្រី និងបុរសមានសិទ្ធិចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីបំពេញតម្រូវការរបស់ពួកគេកាន់តែប្រសើរឡើង។ រហូតមកដល់បច្ចុប្បន្ន ៖ ការចូលរួមរបស់ប្រជាពលរដ្ឋនៅកម្រិត ក្រុង/ស្រុក នៅមានកម្រិតខ្លាំង ដោយសារឱកាសក្នុងការចូលរួមនៅមានកំណត់ ដែលផ្តល់ដោយរដ្ឋបាលក្រុង/ស្រុក និងកង្វះខាត ការអនុវត្តយន្តការចូលរួមរបស់ប្រជាពលរដ្ឋលើផ្នែកផ្គត់ផ្គង់សេវានៃអភិបាលកិច្ច ក្រុង/ស្រុកនៅមានកម្រិត។ វិសាលភាពនៃការសម្រេចចិត្ត ការផ្ទេរមុខងារ និងការអនុវត្តថវិកានៅកម្រិត ក្រុង/ស្រុកដែលទើបតែធ្វើការផ្ទេរមុខងារទៅរដ្ឋបាលក្រុង/ស្រុក នៅមានចន្លោះខ្វះខាតទាក់ទងជាមួយការយល់ដឹង អំពីដំណើរការក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅកម្រិត ក្រុង/ស្រុក ក្នុងចំណោមប្រជាពលរដ្ឋ អង្គការសង្គមស៊ិវិល និងអង្គការសហគមន៍មូលដ្ឋាន និងការប្រើប្រាស់ឱកាសដែលមានស្រាប់សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ និងអង្គការសហគមន៍មូលដ្ឋានជាមួយរដ្ឋបាលក្រុង/ស្រុកក៏នៅមានកម្រិតដែរ។

ដើម្បីដោះស្រាយបញ្ហា និងកង្វល់ទាំងនេះ លេខាធិការដ្ឋាន អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) បានចងក្រងករណីសិក្សាចំនួន ៧ លើ ការចូលរួមរបស់ពលរដ្ឋនៅនៅថ្នាក់ក្រុង-ស្រុក ក្រុងបាត់ដំបង បាណន់ ថ្មគោល បវេល មោងឬស្សី រតនមណ្ឌល និងស្រុកកំរៀង ខេត្តបាត់ដំបង ដោយផ្អែកលើបទពិសោធន៍របស់សមាជិកអង្គការ CPDD រួមមាន អង្គការបណ្តុះបណ្តាលសហគមន៍ ដើម្បីការអភិវ្ឍន៍ (CTOD) និងអង្គការអភិវឌ្ឍន៍ស្ត្រី (AS)។ បានធ្វើការសិក្សាអំពី ការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងយន្តការដែលមានស្រាប់របស់រដ្ឋបាលក្រុង/ស្រុក នៅកម្រិត ក្រុង/ស្រុក និងបានធ្វើការចងក្រងជាឯកសារតាមរយៈការសម្ភាសន៍ ជាមួយ អង្គការសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ដើម្បីប្រមូល ទស្សនៈ និងការយល់ឃើញរបស់ ពួកគេចំពោះយន្តការចូលរួមដែលមានស្រាប់។ ករណីសិក្សាចំនួន៧ ត្រូវបានចង់ក្រង និងអនុវត្តនៅក្នុងកម្រិតក្រុង-ស្រុក ដែលជាដៃគូទាំង៧ នៃខេត្តបាត់ដំបង។ របាយការណ៍សិក្សា និងបញ្ជីអនុសាសន៍ចំនួន ៧ ត្រូវបានធ្វើដោយផ្អែកលើការរកឃើញក្នុង ករណីសិក្សាចំនួន ៧ កិច្ចប្រជុំពិគ្រោះយោបល់នៅកម្រិតក្រុង/ស្រុក និងការសម្ភាសន៍ ជាមួយប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងអង្គការសហគមន៍មូលដ្ឋានដែលមានចំនួន ៣៦៧ នាក់ (ស្រី ២០៩ នាក់) ។ ក្នុងនោះបញ្ជីអនុសាសន៍រួមរវាងរដ្ឋបាលក្រុង-ស្រុកគោលដៅទាំង ៧និងអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រុង-ស្រុកត្រូវបានបង្កើតឡើង និងអនុម័តដោយរដ្ឋបាលក្រុង/ស្រុក ក្នុងគោលដៅទាំង៧ និងអង្គការសង្គមស៊ីវិលតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់រួមគ្នានៅរដ្ឋបាលថ្នាក់ក្រុង-ស្រុក ដែលធ្វើឡើងនៅចន្លោះខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២១។ បញ្ជីអនុសាសន៍រួមត្រូវបានបង្ហាញដល់ថ្នាក់ខេត្ត និងថ្នាក់ជាតិតាមរយៈកិច្ចប្រជុំបច្ចេកទេសភាពជាដៃគូនៅក្នុងសិក្ខាសាលាថ្នាក់ខេត្ត និងថ្នាក់ជាតិស្តីពីបញ្ជីអនុសាសន៍រួម ដើម្បីចាត់អាទិភាពលើអនុសាសន៍ និងកំណត់សកម្មភាពរួមគ្នាក្នុងការអនុវត្តន៍បន្តសម្រាប់រដ្ឋបាលថ្នាក់ខេត្ត និងថ្នាក់ជាតិ។ បញ្ជីនៃអនុសាសន៍រួមរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងយន្តការចូលរួមរបស់ប្រជាពលរដ្ឋនៅកម្រិតក្រុង/ស្រុកទាំង៧ នឹងត្រូវបានបង្កើត និងទទួលយកដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាល ក្រុង-ស្រុកគោលដៅទាំង៧ ក្នុងខេត្តបាត់ដំបង។